ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ ទៅជាវិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ

- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា១..**

ត្រូវបានប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ ទៅជា «វិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រះសីហនុ» ហៅកាត់ថា «វ.ព.ព» និងជាភាសាអង់គ្លេស «Polytechnic Institute of Preah Sihanouk» ហៅកាត់ថា «P.I.P»។ វិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រះសីហនុនេះជាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈសាធារណៈ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការងារនិងបណ្តុះណ្តាលវិជ្ជាជីវៈ និងមានទីតាំងស្ថិតនៅ ក្រុមទី១៥ ភូមិ២ សង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

**មាត្រា២..**

វ.ព.ព មានភារកិច្ចធ្វើការបណ្តុះបណ្តាល ៖

- កម្រិតវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈសិក្សារយៈពេលខ្លីក្រោម១ ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១ , ២ និង៣ សិក្សារយៈពេល ១ឆ្នាំ ឬ២ឆ្នាំ ឬ៣ឆ្នាំ ដែលមានយ៉ាងតិច ៣០ក្រេឌីត (សម្រាប់មួយកម្រិត)
- កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឯកទេស បរិញ្ញាបត្ររងសិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ដែលមានយ៉ាងតិច ៦០ក្រេឌីត
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា ឬឯកទេសសញ្ញាបត្រវិស្វករ សិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ដែលមានយ៉ាងតិច ១២០ក្រេឌីត។

**មាត្រា៣..**

វ.ព.ព បណ្តុះបណ្តាលលើមុខជំនាញដូចខាងក្រោម ៖

- វិស្វកម្មអគ្គិសនីនិងវិស្វកម្មអេឡិចត្រូនិច
- វិស្វកម្មសំណង់ស៊ីវិល
- ព័ត៌មានវិទ្យា
- គ្រប់គ្រងពាណិជ្ជកម្ម
- សណ្ឋាគារនិងទេសចរណ៍
- ភាសាបរទេស។

នៅថ្ងៃអនាគត វិទ្យាស្ថាននេះអាចបើកជំនាញ ឬឯកទេសដទៃទៀតដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៤.-**

លក្ខខណ្ឌទទួលសិស្ស-និស្សិតឲ្យចូលរៀន ៖

- កម្រិតវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈ បេក្ខជនជាសិក្ខាកាម សិស្ស-និស្សិត ប្រជាពលរដ្ឋ និងមន្ត្រីរាជការទូទៅ
- កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ បេក្ខជនបានរៀនចប់ថ្នាក់ទី៩ នៃមធ្យមសិក្សាបឋមភូមិ ឬវិញ្ញាបនបត្រស្គាល់ចម្លងបន្តជំនាញឬវិញ្ញាបនបត្រដែលមានតម្លៃស្មើ
- កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ២ បេក្ខជនដែលមានសញ្ញាបត្របច្ចេកទេស និងវិជ្ជា-ជីវៈ ១
- កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ៣ បេក្ខជនដែលមានសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ២
- កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឯកទេស បរិញ្ញាបត្ររង បេក្ខជនមានសញ្ញាបត្រមធ្យម-សិក្សា ទុតិយភូមិ(ជាប់ ឬធ្លាក់)ឬមានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា ឯកទេសសញ្ញាបត្រវិស្វករ បេក្ខជនមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស បរិញ្ញាបត្ររងឬសញ្ញាបត្រ ដែលមានតម្លៃស្មើ។

វិទ្យាស្ថានត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកំណត់អំពីការជ្រើសរើសសិស្ស-និស្សិតឲ្យចូលរៀននៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

**មាត្រា៥.-**

**វ.ព.ព** ត្រូវមានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍ និងការងារពាក់ព័ន្ធផ្សេងៗទៀតរបស់វិទ្យាស្ថាន។

**មាត្រា៦.-**

**វ.ព.ព** ត្រូវដឹកនាំដោយនាយកមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងនាយករងមួយចំនួនមានឋានៈស្មើអនុប្រធាននាយកដ្ឋាន តាមការចាំបាច់។

រចនាសម្ព័ន្ធរបស់ **វ.ព.ព** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៧.-**

សិស្ស-និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់ **វ.ព.ព** ហើយទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សាត្រូវទទួលបានវិញ្ញាបនបត្រឬសញ្ញាបត្រតាមកម្រិតនិងឯកទេសដែលបានសិក្សា។ វិញ្ញាបនបត្រ ឬ

សញ្ញាបត្រដែលផ្តល់ឲ្យដោយ **វ.ព.ព** នឹងត្រូវទទួលស្គាល់ ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងករណី **វ.ព.ព** បានបំពេញនិងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៨..**

មន្ត្រីដែលបម្រើការងារនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ ត្រូវនៅបំពេញភារកិច្ចតាមតួនាទីរបស់ខ្លួនរហូតដល់មានការតែងតាំងថ្មី ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៩..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១០..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីរដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ០២ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**

សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារកាលប្បវត្តិ